# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ ៦៤៣ប្រក កសក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់ថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទសិប្បកម្មក្នុងដែននេសាទសមុទ្រ

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ   រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុក្រឹត្យទាំងឡាយដែលដំឡើង បំពេញបន្ថែម និងកែសម្រួល នាយកដ្ឋានមួយចំនួននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខៈ (៨៥៥)២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

## សម្រេច

**ប្រការ១._**

ប្រកាសអន្តរក្រសួងនេះ មានគោលបំណងកំណត់ថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទសិប្បកម្មដែលប្រើប្រាស់ក្នុងដែននេសាទសមុទ្រ លើកលែងតែការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ តាមប្រកាសលេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ២._**

ថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទសិប្បកម្មក្នុងដែននេសាទសមុទ្រ ត្រូវបានគណនាតាមប្រភេទ ប្រវែង ទំហំ ឬចំនួនឧបករណ៍ សម្ភារនេសាទ ឬកម្លាំងសេះនៃមធ្យោបាយនេសាទ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ប្រកាសអន្តរក្រសួងនេះ។ ចំពោះប្រភេទឧបករណ៍នេសាទដែលមានប្រសិទ្ធភាពសមាមាត្រទៅនឹងកម្លាំងសេះនៃមធ្យោបាយអូសទាញដែលមិនមែនជាប្រភេទម៉ាស៊ីនទូក កាណូត ត្រូវគណនាសម្រាប់យកថ្លៃឈ្នួលដែននេសាទស្មើនឹង៥០%។

**ប្រការ៣._**

ចំណូលបានមកពីថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទសិប្បកម្មក្នុងដែននេសាទសមុទ្រ ត្រូវបង់ចូលថវិកាជាតិទាំងស្រុងនៅរតនាគារខេត្តសាមី។

**ប្រការ៤._**

ប្រកាសអន្តរក្រសួងនេះ អាចធ្វើការកែសម្រួលក្នុងករណីចាំបាច់។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

អគ្គលេខាធិការ អគ្គាធិការ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ[illegible] ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ

**តារាងឧបសម្ព័ន្ធ**

ភ្ជាប់ប្រកាសអន្តរក្រសួងនេះលេខ ៦៤៣ ប្រក កសក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៥

ស្តីពី "ការកំណត់ថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទសិប្បកម្មក្នុងដែននេសាទសមុទ្រ"

| ល.រ | ឈ្មោះ ឧបករណ៍នេសាទ | ចំនួននិងប្រវែង | ក្រឡា | ឯកតា | ថ្លៃឈ្នួលដែននេសាទ |
|---|---|---|---|---|---|
| ១ | ឈ្នក់ក្តាម | លើសពី១០០ឈ្នក់ | | ១ ឈ្នក់ | ១.០០០ ៛ ០០ |
| ២ | ទូកអូសឈ្នាងគ្រែងឈាម | មិនលើសពី១ម៉ែត្រ | ២ស.មឡើង | ១ សេះ | ១៥.០០០ ៛ ០០ |
| ៣ | ទូកអូសឈ្នាងគ្រំក្រឡាហូល | មិនលើសពី១,២ម៉ែត្រ | ១,២ស.មឡើង | ១ សេះ | ៤០.០០០ ៛ ០០ |
| ៤ | ផ្លាក់មឹកសំបកខ្យង | លើសពី១.៥០០ខ្យង | | ១ ខ្យង | ១០០ ៛ ០០ |
| ៥ | មងក្តាម | លើសពី២.០០០ម៉ែត្រ | ៦ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ៦ | មងត្រីកាតាំង | លើសពី២.០០០ម៉ែត្រ | ៦ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ៧ | មងត្រីក្បក | លើសពី២.០០០ម៉ែត្រ | ៣,៥ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ៨ | មងត្រីកាម៉ុង | លើសពី២.០០០ម៉ែត្រ | ៤ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ៩ | មងត្រីការ៉ាវ | លើសពី២.០០០ម៉ែត្រ | ៧ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ១០ | មងត្រីបេកា | លើសពី២.០០០ម៉ែត្រ | ៨ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ១១ | មងត្រីស | លើសពី២.០០០ម៉ែត្រ | ២ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ១២ | មងត្រីផ្ទោង | លើសពី២.០០០ម៉ែត្រ | ២,៥ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ១៣ | មងបង្គា៣ជាន់ | លើសពី២.០០០ម៉ែត្រ | ៣,៨ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ១៤ | មងបង្គា១ជាន់ | លើសពី២.០០០ម៉ែត្រ | ៣,៥ស.មឡើង | ១ ម៉ែត្រ | ២០០ ៛ ០០ |
| ១៥ | មងហ៊ុម | លើសពី៥០០ម៉ែត្រ | ៣ស.មឡើង | ១ ម៉ែត្រ | ១.៥០០ ៛ ០០ |
| ១៦ | លបក្តាម | លើសពី៥០០លប | ៦ស.មឡើង | ១ លប | ៥០០ ៛ ០០ |
| ១៧ | លបខ្យង | លើសពី១០០លប | | ១ លប | ១.៥០០ ៛ ០០ |
| ១៨ | លបត្រីមុខកាត់ធំជាង០,៥-១ម៉ែត្រ | លើសពី៣០លប | | ១ លប | ៥.០០០ ៛ ០០ |
| ១៩ | លបត្រីមុខកាត់ធំជាង១ម៉ែត្រ | លើសពី៣០លប | | ១ លប | ៣០.០០០ ៛ ០០ |
| ២០ | លបមឹក | លើសពី១០០លប | ៤ស.មឡើង | ១ លប | ១.៥០០ ៛ ០០ |
| ២១ | សន្ទូចបបែល | លើសពី១.៥០០ផ្លែ | | ១ ផ្លែ | ១០០ ៛ ០០ |
| ២២ | សន្ទូចរនង | លើសពី១.៥០០ផ្លែ | | ១ ផ្លែ | ៥០០ ៛ ០០ |
| ២៣ | អួនខូវ ( មងខូវ ) | លើសពី២០០ម៉ែត្រ | ៣ស.មឡើង | ១ ម៉ែត្រ | ៣.៥០០ ៛ ០០ |
| ២៤ | អួនហ៊ុមកៀនច្រាំង | លើសពី២០០ម៉ែត្រ | | ១ ម៉ែត្រ | ១.៥០០ ៛ ០០ |
| ២៥ | អួនទិត និងអួនផ្សេងៗ | | | ១ ម៉ែត្រ | ៤.៦០០ ៛ ០០ |
| ២៦ | ទូកអួនអូស | | ៤ស.មឡើង | ១ សេះ | ២៧.០០០ ៛ ០០ |

<u>បញ្ជាក់:</u> បញ្ចប់ត្រឹមលេខរៀងទី២៦ គត់

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត វ៉េង សាខុន** **បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**